CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**
ថ្ងៃទី 4 ខែកុម្ភៈ ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov
សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិចដាស់តឿន ប្រជាពលរដ្ឋឱ្យធ្វើការអបអរសាទរ ចុងសប្តាហ៍ស៊ូបភើ បូល (Super Bowl) ប្រកបដោយសុវត្ថិភាព

ឡុងប៊ិច, CA - ដោយចុងសប្តាហ៍ស៊ូបភើ បូល (Super Bowl) នឹងឈានចូលមកដល់ សាលាក្រុងឡុងប៊ិចកំពុងដាស់តឿន ប្រជាពលរដ្ឋឱ្យធ្វើការអបអរសាទរ ប្រកបដោយសុវត្ថិភាព ដោយគោរពតាម បទបញ្ជានៅផ្ទះមានសុវត្ថិភាពជាង និង ពិធីសារសុវត្ថិភាព សំខាន់ៗ ផ្សេងទៀត ដើម្បីជួយកាត់បន្ថយ ការឆ្លងរាលដាល COVID-19 ហើយធានាឱ្យមានសុវត្ថិភាព ដល់អ្នកគ្រប់គ្នា ។

ខណៈការនៅផ្ទះ នៅតែជាកត្តាសំខាន់ ក្នុងការកាត់បន្ថយ ការឆ្លងរីករាលដាល COVID-19 និងសង្គ្រោះជីវិតមនុស្ស សាលាក្រុងលើកទឹកចិត្តឱ្យអ្នកគ្រប់គ្នា ស្វែងរកជម្រើសផ្សេងទៀត ក្នុងការទាក់ទង ជាមួយអ្នកផ្សេង និងធ្វើការអបអរសាទរ ចុងសប្តាហ៍ស៊ូបភើ បូល (Super Bowl) នេះ ប្រកបដោយសុវត្ថិភាព ដូចជា ទំនាក់ទំនង ជាមួយគ្រួសារ និងមិត្តភក្តិ តាមអ៊ីនធឺណែត ដោយរៀបចំពិធីជប់លៀង Super Bowl តាមវីដេអូ និងចែករំលែករូបថត និងវីដេអូ បង្ហាញពីពេលសប្បាយរីករាយ នឹងព្រឹត្តិការណ៍កីឡាដ៏ធំនេះ តាមវេទិកាជជែកជាក្រុម (group chat) ។

**ចំណុចត្រូវប្រុងប្រយ័ត្ន ចំពោះសុវត្ថិភាព សម្រាប់ការជួបជុំ និងសម្រាប់បុគ្គលម្នាក់ៗ**
ប្រជាពលរដ្ឋឡុងប៊ិច ដែលមានបំណងមើល ព្រឹត្តិការណ៍កីឡាដ៏ធំនេះ ត្រូវបានលើកទឹកចិត្ត ឱ្យមើលនៅផ្ទះ ជាមួយសមាជិកគ្រួសាររបស់ខ្លួន ដោយសារការជួបជុំ ជាមួយអ្នកមកពីគ្រួសារផ្សេងៗ គ្នា អាចនាំឱ្យមានហានិភ័យឆ្លងវីរុស ជាសារវ័ន្ត ។ ការជួបជុំគ្នា លក្ខណៈសង្គម ត្រូវធ្វើឡើងនៅទីវាល ហើយត្រូវមានសមាជិក មិនលើសពី 15 នាក់ មកពីគ្រួសារ មិនលើសពី នោះទេ ។ បុគ្គលដែលចូលរួម ក្នុងការជួបជុំ មានការអនុញ្ញាតនោះ គួរតែអនុវត្ត វិធានការសុវត្ថិភាពត្រឹមត្រូវ ជាប់ជានិច្ច ដូចជា រក្សាគម្លាត យ៉ាងហោចណាស់ឱ្យបាន ប្រាំមួយហ្វីត ពីអ្នកផ្សេងទៀត ដែលមកពីគ្រួសារផ្សេង, ពាក់ម៉ាស់, លាងសម្អាតដៃ ឱ្យបានញឹកញាប់ និងកម្ចាត់មេរោគលើផ្ទៃ ដែលមានមនុស្សប៉ះពាល់ច្រើន ។

**លក្ខខណ្ឌតម្រូវ ផ្នែកសុវត្ថិភាព សម្រាប់ភោជនីយដ្ឋាន**
ភោជនីយដ្ឋាន, ទីផ្តល់សេវាភេសជ្ជៈ, ហាងលក់ភេសជ្ជៈ, បា, ក្លឹបកំសាន្ត, សិប្បកម្មបិតគ្រឿងស្រវឹង និងកន្លែងបិតស្រា ដែលមានទូរទស្សន៍ចាក់ឱ្យភ្ញៀវទស្សនា រួមទាំង ព្រឹត្តិការណ៍កីឡា Super Bowl ថ្ងៃអាទិត្យ ត្រូវបានរំពឹងឱ្យគោរពតាម លក្ខខណ្ឌតម្រូវ ខាងក្រោមនេះ ដូចមានបញ្ជាក់នៅក្នុងពិធីសារ នៃបទបញ្ជាសុខាភិបាល ឱ្យនៅផ្ទះមានសុវត្ថិភាពជាង ៖

- ធុរកិច្ច អាចដំណើរការទៅបាន តែនៅទីវាល ប៉ុណ្ណោះ

- គ្រឿងស្រវឹង មានបម្រើជូន តែនៅក្នុងប្រតិបត្តិការតែមួយ ជាអាហារពិត សម្រាប់អង្គុយទទួលទាន, សេវាអាហារនៅនឹងកន្លែង
- តុនៅទីវាល ត្រូវដាក់ឱ្យដាច់ដោយឡែកពីគ្នា ដោយមានគម្លាត ជាអប្បបរមា ប្រាំបីហ្វីត ។
- កន្លែងអង្គុយ នៅទីវាល ត្រូវបានកំហិត ឱ្យមានមនុស្សអង្គុយ មិនលើសពី ប្រាំមួយនាក់ ដែលមកជប់លៀងតែមួយ នៅតុតែមួយ
- អតិថិជន ត្រូវនៅអង្គុយនៅតុដដែល លើកលែងតែពេល ចាំបាច់ត្រូវទៅបន្ទប់ទឹក, ទូទាត់វិក្កយបត្រ ឬ បញ្ជាទិញអាហារ និងភេសជ្ជៈ
- អតិថិជនមិនត្រូវបានអនុញ្ញាតឱ្យ ទទួលទាន អាហារ ឬ ភេសជ្ជៈ រួមទាំង គ្រឿងស្រវឹង នោះទេ ប្រសិនបើពួកគេមិនអង្គុយនៅតុ
- របាំងមុខ ត្រូវដោះចេញ តែនៅពេលដែលអតិថិជនអង្គុយនៅតុ ត្រង់កន្លែងទទួលទាន នៅទីវាល មានកំណត់រួច សម្រាប់ការទទួលទានអាហារ ឬ ភេសជ្ជៈ ប៉ុណ្ណោះ
- បុគ្គលិកបន្ថែមទៀត គួរមានវត្តមាន នៅតាមដានមើល និងចាត់ចែង អតិថិជន ដូចជា តែមិនកម្រិតត្រឹម ៖
    - ធានាឱ្យមាន ការរក្សាគម្លាតរាងកាយ ក្នុងចំណោមអតិថិជន
    - ធានាឱ្យអតិថិជន មិនទទួលទានភេសជ្ជៈ ឬអាហារ ខណៈដែលគាត់មិនអង្គុយនៅតុ
    - ធានាមិនឱ្យមាន មនុស្សកកកុញគ្នា នៅខាងមុខ ទូរទស្សន៍ ឬ ផ្ទៃបញ្ចាំងរូបភាព
    - ធានាឱ្យមានផ្លូវដើរ និងច្រកសាធារណៈ បើកទូលាយ ហើយ ADA អាចចេញចូលបាន

សាលាក្រុងកំពុងត្រៀមលក្ខណៈ ចាត់វិធានការច្បាប់ ចំពោះធុរកិច្ចណា ដែលខកខានមិនគោរពតាម បទបញ្ជាសុខាភិបាល ឱ្យនៅផ្ទះមានសុវត្ថិភាពជាង ដែលអាចមានដូចជា តែមិនកម្រិតត្រឹម ៖ ដីការដ្ឋប្បវេណី ឬ ដីកាព្រហ្មទណ្ឌ, ការលុបចោលលិខិតអនុញ្ញាតឱ្យបើកស្តង់តាមឧទ្យានជាបណ្តោះអាសន្ន, ការលុបចោលលិខិតអនុញ្ញាតសកម្មភាព នៅទីវាល (OAP) ដើម្បីបើកប្រតិបត្តិការ នៅទីវាល ក្នុងពេលមានរោគឆ្លងរាតត្បាត ជាសាកល, ការលុបចោល និង/ឬ ការព្យួរ អាជ្ញាប័ណ្ណធុរកិច្ច, ការលុបចោល និង/ឬ ការព្យួរ លិខិតអនុញ្ញាតសុខាភិបាល, និង ការលុបចោល និង/ឬ ការព្យួរ អាជ្ញាប័ណ្ណគ្រប់គ្រងភេសជ្ជៈស្រវឹង (ABC) ។

សាលាក្រុងក៏រំឭកប្រជាពលរដ្ឋផងដែរ អំពីគន្លឹះសុវត្ថិភាព និងចំណុចត្រូវប្រុងប្រយ័ត្នផ្សេងៗទៀត ដែលត្រូវអនុវត្ត នៅចុងសប្តាហ៍ស៊ូបភើ បូល (Super Bowl) នេះ ។

**ការបើកបរ & សុវត្ថិភាពអ្នកថ្មើរជើង**

នាយកដ្ឋាននគរបាលឡុងប៊ិច នឹងមានមន្ត្រីបន្ថែមទៀត សម្រាប់ល្បាត នៅថ្ងៃទី 7 ខែកុម្ភៈ ដើម្បីបញ្ចៀសអ្នកបើកបរ មិនឱ្យបើកបរ ក្រោមឥទ្ធិពលគ្រឿងស្រវឹង និង/ឬ គ្រឿងញៀន ។ គ្រឿងស្រវឹង មិនមែនជាកត្តាតែមួយមុខ ដែលអាចនាំឱ្យមាន ការចុះខ្សោយ និងអាចនាំទៅ DUI នោះទេ ។ ឱសថ តាមវេជ្ជបញ្ជា, ឱសថទិញតាមឱសថស្ថាន និងកញ្ឆា អាចមានឥទ្ធិពលលើសមត្ថភាព របស់លោកអ្នក ក្នុងការបើកបរ ប្រកបដោយសុវត្ថិភាព បានផងដែរ ។ អ្នកថ្មើរជើងគួររក្សាការប្រុងប្រយ័ត្ន អំពីបរិវេណជុំវិញខ្លួន ជាពិសេស នៅពេលយប់ និងនៅពេលឆ្លងថ្នល់ ទោះបីជាដើរឆ្លង លើគំនូសឆ្លងថ្នល់ក្តី ។

ទោះបីជាពិធីជប់លៀងមើលព្រឹត្តិការណ៍ជាច្រើន ត្រូវបានធ្វើឡើង តាមអ៊ីនធឺណែតក្តី ជាការចាំបាច់ត្រូវរៀបផែនការចាត់តាំងអ្នកបើកបរស្ងាងម្នាក់ ឬ នៅផ្ទះនាពេលយប់នោះ ។

CITY OF LONGBEACH

PRESS RELEASE

មូលនិធិ សម្រាប់ការអនុវត្តច្បាប់ នៅព្រឹត្តិការណ៍ថ្ងៃអាទិត្យស៊ូបភើ បូល (Super Bowl) នេះ ត្រូវបានផ្តល់ឱ្យ ដោយប្រាក់ជំនួយ ពីការិយាល័យសុវត្ថិភាពចរាចរណ៍ កាលីហ្វ័រញ៉ា តាមរយៈរដ្ឋបាលសុវត្ថិភាពចរាចរណ៍ផ្លូវហាយវេជាតិ ។

**កាំជ្រួច & សកម្មភាពខុសច្បាប់ផ្សេងទៀត**

កាំជ្រួច លក្ខណៈផ្ទាល់ខ្លួនទាំងអស់ រួមទាំង កាំជ្រួចមានដាក់ស្លាកថា មានសុវត្ថិភាព និងត្រឹមត្រូវផងដែរ ត្រូវបានហាមឃាត់ នៅក្នុងទីក្រុងឡុងប៊ិច ។ កាំជ្រួចបង្ករឱ្យមាន ការខូចខាត ផ្នែកអចលនទ្រព្យ មានតម្លៃ ដប់លានដុល្លារ ជារៀងរាល់ឆ្នាំ ហើយបង្ករឱ្យមានរបួសស្នាមជាច្រើន ដែលភាគច្រើន បានកើតមានទៅលើកុមារ ។ ដោយមានភាពតឹងតែង ជាបន្ត ផ្នែកសមត្ថភាពទទួលអ្នកជំងឺ របស់មន្ទីរពេទ្យ ដោយសារតែ COVID-19, ជាការសំខាន់ ខ្លាំងណាស់ ដែលត្រូវជៀសវាង អាកប្បកិរិយាបង្ករហានិភ័យ ដូចជា ការដុតកាំជ្រួច ។

កាំជ្រួចដែលដុតបង្ហោះឡើង នៅតាមភូមិឋាន ជាពិសេស កាំជ្រួចដែលដំណើរការខុសពីការរំពឹងទុក អាចដាស់ការចងចាំមិនល្អ របស់អតីតយុទ្ធជន និងអ្នករស់រានសល់ជីវិត ពីអំពើហិង្សាប្រើប្រាស់កាំភ្លើង ដែលមានបញ្ហាតានតឹងអារម្មណ៍ ក្រោយឆ្លងកាត់ព្រឹត្តការណ៍មិនល្អរួច ។ សម្លេងក៏បង្ករឱ្យមាន ការភិតភ័យ សម្រាប់សត្វជាច្រើនផងដែរ ហើយជម្រកសង្គ្រោះ មានពោរពេញទៅដោយ សត្វរត់ចោលផ្ទះ ជារៀងរាល់ឆ្នាំ ។

មានមធ្យោបាយ មួយចំនួន សម្រាប់រាយការណ៍ អំពីសកម្មភាពបាញ់កាំជ្រួច ខុសច្បាប់ នៅឡុងប៊ិច ៖

- សូមដាក់ ពាក្យបណ្តឹង អំពីកាំជ្រួច ឬ បញ្ជូន រូបថត និងវីដេអូ បង្ហាញពី សកម្មភាពបាញ់កាំជ្រួចខុសច្បាប់ទៅការិយាល័យព្រះរាជអាជ្ញាក្រុង ។
- សូមទូរសព្ទទៅលេខ (562) 435-6711 មិនមែនសម្រាប់ករណីអាសន្ន នៅមជ្ឈមណ្ឌលគមនាគមន៍ ដើម្បីរាយការណ៍ អំពីការប្រើប្រាស់ និង/ឬ លក់ កាំជ្រួច ។
- សូមផ្ញើអ៊ីមែល ទៅផ្នែកកិច្ចការភ្ញៀវ អំពីទីកន្លែង ដែលសកម្មភាពកើតមាន ហើយផ្តល់អាសយដ្ឋាន វីដេអូ លេខយានជំនិះ រូបថត និងព័ត៌មានផ្សេងៗ ទៀត ដែលអាចយកមកធ្វើការស៊ើបអង្កេតបាន ។ សូមរួមបញ្ចូលឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទ របស់លោកអ្នក ដើម្បីឱ្យគេអាចទាក់ទង ទៅលោកអ្នកបាន តាមការចាំបាច់ ៖
    - LBPDNorth@longbeach.gov
    - LBPDSouth@longbeach.gov
    - LBPDEast@longbeach.gov
    - LBPDWest@longbeach.gov
- សម្រាប់ករណីអាសន្ន សូមទូរសព្ទទៅលេខ 9-1-1 ។

ការបាញ់កាំភ្លើង លក្ខណ: «អបអរសាទរ» ត្រូវបានចាត់ជា ការបាញ់ ដោយខុសច្បាប់ ហើយអាចបង្ករឱ្យមានគ្រោះថ្នាក់ ។ ការបាញ់កាំភ្លើង ដើម្បីធ្វើការអបអរសាទរ អាចនាំឱ្យមាន របួសស្នាម ឬមរណភាព ចំពោះជនណាម្នាក់ ហើយជនល្មើសត្រូវជាប់ពន្ធនាគារ ។

សម្រាប់ព័ត៌មានបន្ថែមទៀត និងគន្លឹះសុត្តិភាព នៅថ្ងៃបុណ្យ សូមមើល សេចក្តីណែនាំ របស់សាលាក្រុង ស្តីពីជំងឺវីរុសកូរ៉ូណា ឆ្នាំ 2019 (COVID-19) សម្រាប់ការអបអរសាទរថ្ងៃបុណ្យ ។

CITY OF LONG BEACH

# PRESS RELEASE

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

ការសាកសួរ ពីប្រព័ន្ធផ្សព្វផ្សាយ អាចបញ្ជូនទៅ មជ្ឈមណ្ឌលទំនាក់ទំនងរួម របស់សាលាក្រុងឡុងប៊ិច តាមរយៈ 562.570.NEWS (6397), jic@longbeach.gov ។

# # #